ធ៧-០២-៤៨ ប្រ.ក

# ប្រកាស
# ស្តីពី
# អនុបាតសាច់ប្រាក់ងាយស្រួលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ត្រូវរក្សាសាច់ប្រាក់ងាយស្រួលឱ្យបានគ្រប់គ្រាន់ជាអចិន្ត្រៃយ៍ យ៉ាងហោចណាស់ស្មើនឹងមួយរយភាគរយ (១០០%)។

**ប្រការ ២**.-

អនុបាតសាច់ប្រាក់ងាយស្រួលនេះត្រូវបានគណនាដូចខាងក្រោម ៖

- ភាគយក : សាច់ប្រាក់ក្នុងដៃ + ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា + ប្រាក់បញ្ញើនៅធនាគារផ្សេងៗ - ប្រាក់ខ្ចីពីធនាគារជាតិនៃកម្ពុជា និងធនាគារផ្សេងៗ (សាច់ប្រាក់ងាយស្រួលសុទ្ធ) + ឥណទានដែលឥណប្រតិទាននៅសល់តិចជាងមួយខែ។
- ភាគបែង : ម្ភៃប្រាំភាគរយ (២៥%) នៃប្រាក់សន្សំដោយស្ម័គ្រចិត្តមិនរួមបញ្ចូលប្រាក់សន្សំកាតព្វកិច្ច។

**ប្រការ ៣**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវផ្តល់ឯកសារពីការគណនាអនុបាតសាច់ប្រាក់ងាយស្រួលប្រចាំខែរបស់ខ្លួនតាមគំរូរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៤**.-

គ្រឹះស្ថានណាមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៥**.-

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៧**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**